ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍
# ប្រជុំរួមប្រចាំខែមេសា ឆ្នាំ២០២១
# របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមេសា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន ទីប្រឹក្សា ជំនួយការ អគ្គលេខាធិការ-រង លោក អ្នកស្រី អ្នកនាងកញ្ញា ជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ចូលរួមតាមបណ្តាញវីដេអូកម្មវិធី Zoom សរុបចំនួន៥០នាក់/គណនី។

## គោលបំណងនៃកិច្ចប្រជុំដើម្បី:

- ធ្វើបច្ចុប្បន្នភាពនៃសកម្មភាពរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ស្ថានភាពរាលដាល និងគោលដៅនៃការឆ្លើយតបនឹងមេរោគអេដស៍ និងបទអន្តរាគមន៍។
- សមិទ្ធផលដែលសម្រេចបាន និងឧបសគ្គ ក្នុងការអនុវត្តផែនការសកម្មភាព និងផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ប្រចាំខែមេសា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉េត។

២- បទបង្ហាញ ស្តីពីការសម្របសម្រួលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដោយ ឯកឧត្តម វេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣- មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី

៤- កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមេសា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែឧសភា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញ ដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

I- **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

១- សកម្មភាពការងារដែលសម្រេចបាន ៖

- រៀបចំសកម្មភាពសម្រាប់អង្គវិប្បសនាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីចំនួន៣លើក ពីវិធីសាស្ត្រ ទី១)- វិភាគការឆ្លើយតប ទី២)- វិភាគរកគម្លាត ទី៣)- កំណត់អាទិភាព។
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤។

២- បញ្ហាប្រឈម ៖

- ស្ថានភាពជំងឺកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- មិនអាចផ្តល់សេវាអប់រំដោយផ្ទាល់បាន។
- មិនអាចចុះទៅជំរុញការងារ *FTC* នៅតាមខេត្តគោលដៅបាន។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ នាថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥។
- បន្តវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពការងារដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ។

៤- សំណូមពរ ៖

- ឯកឧត្តម អគ្គលេខាធិការ ស្នើសុំឱ្យ អគ្គលេខាធិការរង ធ្វើបទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំប្រចាំខែ ម្តងម្នាក់ៗ សម្រាប់ខែក្រោយៗ។

II- **បទបង្ហាញ** ***ស្តីពីការវិភាគរបស់ក្រុមការងារវាយតម្លៃលទ្ធផលការរំពឹងទុកថ្នាក់ប្រទេស*** (PCE) ស្តីអំពី ***ការចូលរួមវិភាគទានរបស់មូលនិធិជំនួយ លើកម្មវិធីមេរោគអេដស៍នៅកម្ពុជា*** ដោយឯកឧត្តម វេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

- ឯកឧត្តម **ទា ផលា** បានទទួលយកនូវប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ស្តីអំពីការងារ GDJ និងHight-Level Meeting ដើម្បីរៀបចំ និងសម្របសម្រួល។
- ចំពោះក្រុមប្រឹក្សាគោលនយោបាយ (Policy Board) សម្រាប់ខែមិថុនា ២០២១ ទោះជាកូវីដ-១៩ នៅតែបិទខ្ទប់ យើងត្រូវតែបន្តអនុវត្ត *គម្រោងពន្លឿនទីក្រុង* (Fast Track City) នៅខេត្ត/រាជធានីទាំង៤ ដែលមានបទពិសោធន៍ក្នុងការឆ្លើយតបនឹងមេរោគអេដស៍។ ក្នុងនោះដោយរៀបចំជា៣ចំណុច គឺទី១)- ថវិកា (Funding) ទី២)- ការបែងចែកមុខងារ (Function) ទី៣)- ការធ្វើប្រតិភូកម្ម (Functionary)។
- ត្រូវអនុវត្តសកម្មភាពផែនការយុទ្ធសាស្ត្រជាតិលើកទី៥ ឱ្យបានរលូន ជោគជ័យ និងមានប្រសិទ្ធភាព។
- ត្រូវយកយន្តការគោលការណ៍ Three Ones Principles ដើម្បីធ្វើការសម្របសម្រួល។

- ក្នុងចក្ខុវិស័យនៃការប្រយុទ្ធនឹងជំងឺអេដស៍គឺ ទី១)- ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ការ (Leadership and ownership) ទី២)- ភាពជាដៃគូ (Partnership) ទី៣)- ការវិនិយោគ (Investment)។
- ស្នើសុំឱ្យមានការកែសម្រួលរចនាសម្ព័ន្ធឱ្យត្រូវគ្នារវាងក្រុម GMC, GDJ ក្រុមការងារបច្ចេកទេស (Technical working group) ក្រុមប្រឹក្សាបច្ចេកទេស (Technical board ) និងក្រុមប្រឹក្សាគោលនយោបាយ (Policy Board) ព្រមទាំងកែសម្រួល ToR របស់ Technical Working Group។
- ឯ.ឧ. វេជ្ជ. ទា ផលា បានស្នើឯ.ឧ. វេជ្ជ. រស់ សីលវ៉ាត់ បង្ហាញនូវសេចក្ដីសម្រេច ០២០ សហវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយស្តីពីអន្តរាគមន៍ជំនួយសង្គមក្នុងកំឡុងពេលអនុវត្តវិធានការបិទខ្ទប់ ដែលអាចជាឱកាសផ្តល់អត្ថប្រយោជន៍ដល់អ្នកផ្ទុកមេរោគអេដស៍ផងដែរ។ ក្នុងនោះឯកឧត្តមបានស្នើគោលគំនិតពិភាក្សាជាមួយឯ.ឧ. កែវ អ៊ូលី តំណាងក្រសួងផែនការក្នុងក្រុមការងារចំពោះកិច្ច ជួយសម្របសម្រួលបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ជាប្រជាជនគោលដៅមួយនៃអន្តរាគមន៍ជំនួយសង្គម ហើយនិងធ្វើការជាមួយបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងដៃគូពាក់ព័ន្ធដើម្បីស្វែងរក និងរៀបចំបញ្ជីអ្នកផ្ទុកមេរោគអេដស៍ដែលរស់នៅក្នុងតំបន់បិទខ្ទប់ជូនក្រុមការងារចំពោះកិច្ច។

## III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- ការឧបត្ថម្ភដល់ក្រុមគ្រួសារ ឬបុគ្គលដែលមានអ្នកផ្ទុកមេរោគអេដស៍ មិនត្រូវរក្សាការសម្ងាត់ចំពោះអ្នកផ្តល់សេវា ឬគ្រូពេទ្យព្យាបាលនោះទេ។ ការរក្សាការសម្ងាត់ វាអាស្រ័យទៅតាមលក្ខខណ្ឌ នៃស្ថានភាពសង្គម នៃភូមិសាស្ត្រ បើសង្គមមានការប្រកាន់ ឬមានការរើសអើងខ្លាំង។ ទាក់ទងនឹងអន្តរាគមន៍ជំនួយសង្គម ក្នុងកំឡុងពេលបិទខ្ទប់ ឯ.ឧ. ទេសរដ្ឋមន្ត្រី ឯកភាពដំណើរការការងារដូចការស្នើឡើងក្នុងបទបង្ហាញរបស់ឯ.ឧ. រស់ សីលវ៉ាត់។

២- បើអ្នកផ្ទុកមេរោគអេដស៍ គាត់ស្ម័គ្រចិត្ត ហើយលែងបារម្ភណ៍ពីរឿងបិទបាំងផ្ទាល់ខ្លួន មកស្នើសុំជំនួយពីអាជ្ញាធរពិសេសក្រុមការងារចំពោះកិច្ច គឺត្រូវផ្តល់ជូនតាមការស្នើសុំរបស់គាត់។

៣- ឯកឧត្តមទេសរដ្ឋមន្ត្រី បានឯកភាពពីការស្នើសុំរបស់ ឯកឧត្តម **ទា ផលា** ក្នុងការកែសម្រួលរចនាសម្ព័ន្ធឱ្យត្រូវគ្នារវាងក្រុម GMC, GDJ ក្រុមការងារបច្ចេកទេស (Technical working group) ក្រុមប្រឹក្សាបច្ចេកទេស (Technical board ) និងក្រុមប្រឹក្សាគោលនយោបាយ (Policy Board)។

៤- ឯកឧត្តមទេសរដ្ឋមន្ត្រី គាំទ្រនូវការកែសម្រួល ToR របស់ GDJ Technical Working Group។ ឯកឧត្តម ទា ផលា ពិនិត្យជាមួយ UNAIDS ធ្វើ ToR ឡើងវិញអំពី GDJ កែប្រែការប្រជុំយ៉ាងតិច៣ខែម្តង។

៥- កិច្ចប្រជុំជាន់ខ្ពស់ (Hight-Level Meeting) ឯកឧត្តម **ទា ផលា** បញ្ជាក់ជាមួយ UNAIDS ពីការរៀបចំអត្ថបទផ្ញើទៅ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដោយរៀបចំអត្ថបទជាពីរ មួយវែងសម្រាប់ផ្សព្វផ្សាយ និងមួយទៀតខ្លី សម្រាប់*សម្តេចតេជោ* អាន រយៈពេល៣នាទី។

៦- ឯកឧត្តមទេសរដ្ឋមន្ត្រី បានគាំទ្រនូវសំណើរបស់ ឯកឧត្តម អគ្គលេខាធិការ ដែលបានស្នើសុំឱ្យអគ្គលេខាធិការរង ធ្វើបទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំប្រចាំខែ។

៧- សូមផ្តល់ជូនឯកឧត្តម **ទា ផលា** រៀបចំចាត់ចែងជួបជាមួយក្រុមពិគ្រោះយោបល់ CCM evolution។ ត្រូវដឹងថាកម្ពុជា ចង់បានអ្វី យើងមាន៣ចំណុច ចំណុចទី១)- ឱ្យ CSO ឬ KP ដែលធ្វើការនៅ CCM ជាតំណាងពិតប្រាកដ ទី២)-រាល់ការប្រជុំ CCC សុំឱ្យមានវេទិកាសម្រាប់ពួកគាត់មានសម្លេងពីការអនុវត្ត ពីជំនួយ ពីបញ្ហាប្រឈម និងសំណូមពរ ទី៣)- CSO ឬ KP ធ្វើការជាមួយគណៈកម្មការអេដស៍របស់យើង។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យបានកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១: ១៨នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១
អ្នកធ្វើកំណត់ហេតុ

**បេជ្ជ. ស៊ុំត ថុចផាន់**

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

**អៀង_មូលី**